# ព្រឹត្តិប័ត្រ
# អំពី
# ការបើកសាលា

*ព្រឹត្តិប័ត្រជូនដំណឹងដល់ មាតាបិតា និងសិស្សានុសិស្ស ដែលប៉ះទង្គិចដោយ ការបិទសាលា ការផ្លាស់ទីកន្លែង និង ការបញ្ចូលគ្នា ដើម្បីត្រៀមខ្លួនសម្រាប់ថ្ងៃចូលរៀនដំបូង*



**ជូនចំពោះ មាតាបិតា អាណាព្យាបាល និងដៃគូនៅក្នុងសហគមន៍៖**

ដោយសារឆ្នាំសិក្សានេះជិតចប់ទៅហើយ ខ្ញុំសូមអរគុណលោកអ្នកចំពោះការចំណាយ ពេលវេលា និងកម្លាំងកាយចិត្ត ទៅលើវិធីនៃគម្រោងការសំខាន់ៗសម្រាប់អាគារ (FMP) និងចង់ផ្តល់ព័ត៌មានថ្មីជូនលោកអ្នក អំពីការត្រៀមខ្លួនរបស់ក្រសួង សម្រាប់បរវេសនកាលនៅខែកញ្ញា។

នៅសរទរដូវនេះ សាលា៥៣នឹងទទួលសិស្សានុសិស្សថ្មី ដោយមូលហេតុនៃការយល់ព្រមពីគណកម្មាធិការកែទម្រង់សាលារៀន (SRC) ឲ្យបិទសាលា ផ្លាស់ទីកន្លែង និងរួមបញ្ចូលគ្នា។ កិច្ចការទាំងអស់មានដំណើរការយ៉ាងរហ័ស ដើម្បីធ្វើយ៉ាងណាឲ្យសាលា និងសិស្សានុសិស្ស មានការងាយស្រួលក្នុងការផ្លាស់ប្តូរ។

មកទល់ពេលនេះ សិស្សានុសិស្សដែលប៉ះទង្គិចដោយការផ្លាស់ប្តូរនេះ បានទទួលលិខិតដែលប្រាប់ពីសាលារបស់ពួកគេសម្រាប់ឆ្នាំសិក្សា ២០១៣-១៤។ ជាបន្ថែមទៀត យើងធ្វើបានសម្រេចជិត៤០ភាគរយ នៃអាគារដែលយើងត្រូវរៀបចំ មុនពេលសាលាចាប់ផ្តើម។ អ្វីៗដែលនៅមិនទាន់ធ្វើ នឹងចាប់ផ្តើមក្រោយពេលចប់ឆ្នាំសិក្សានៅថ្ងៃទី២១ ខែមិថុនា។

ក្រសួងសន្យាផ្តល់ដំណឹងដល់ សិស្សានុសិស្ស មាតាបិតា បុគ្គលិក និងដៃគូនៅក្នុងសហគមន៍ អំពីវិធីនេះ។ យើងខ្ញុំនឹងផ្តល់ព័ត៌មានថ្មីៗតាមវិបសៃអំពីការបើកសាលា (www.philasd.org/schoolopening) ហើយផ្សព្វផ្សាយព្រឹត្តិប័ត្រស្តីអំពីការបើកសាលា រៀងរាល់ពីរសប្តាហ៍។ ការផ្តល់ព័ត៌មានអំពី ស្ថានភាពអាគារ សណ្តាប់ធ្នាប់ និងសន្តិសុខ កម្មវិធីសម្រាប់សិស្ស និង កាលវិភាគសម្រាប់ការដើរមើលសាលាដែលទទួលសិស្ស នឹងចែកជូនតាមអ៊ិនធ័រណិត និងតាមព្រឹត្តិប័ត្រ។

នាយកសាលារបស់កូនលោកអ្នកក៏ទាក់ទងទៅលោកអ្នកនៅក្នុងរដូវក្តៅនេះដែរ ដើម្បីផ្តល់ព័ត៌មានបន្ថែមទៀត។

ខ្ញុំជឿជាក់ថា តាមរយៈការរៀបចំអាគារ និងធនធាន របស់យើងឲ្យសមស្របជាមួយការចុះឈ្មោះរៀនរបស់សិស្ស គឺយើងបានរៀបចំមូលដ្ឋានគ្រឹះ ដើម្បីបង្កើនឱកាសសិក្សាសម្រាប់សិស្សានុសិស្សទាំងអស់។ ខ្ញុំសុំឲ្យលោកអ្នកបន្តការចូលរួមក្នុងវិធីនេះ ហើយផ្ញើសំណួរលោកអ្នកតាមអ៊ីមែល schoolopening@philasd.org។ តាមការរួបរួមគ្នា យើងអាចធ្វើយ៉ាងណាឲ្យសិស្សានុសិស្សនៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យា ទទួលការអប់រំដែលពួកគេគប្បីនឹងទទួល។

សូមអរគុណជាថ្មីម្តងទៀត ចំពោះការគាំទ្ររបស់លោកអ្នក



William R. Hite, Jr., Ed.D.

## តើយើងធ្វើបានដូចម្តេច?

ចំណុចសំខាន់ៗអំពីការរីកចម្រើនក្នុងការរៀបចំសាលាទទួលសិស្សរបស់ក្រសួង សម្រាប់ឆ្នាំសិក្សាថ្មី៖

**ចំនួនភាគរយ នៃ..**

| | |
|---|---|
| **សាលាទទួលសិស្ស ដែលបានទទួលការវាយតម្លៃអាគារ** | ១00% |
| **សាលាទទួលសិស្ស ដែលបានទទួលការរៀបចំអាគាររួចរាល់** | ៤0% |
| **សាលាដែលបិទ ដែលបានទូទាត់បញ្ជីរួចរាល់ សម្រាប់កម្មវិធីថ្មីៗ** | ៩១% |
| **សិស្សានុសិស្សដែលគេបានផ្ញើលិខិតប្រាប់ពីសាលារបស់ពួកគេសម្រាប់ឆ្នាំសិក្សា ២០១៣-១៤** | ១00% |

**ទាក់ទងដើម្បីទទួលអ៊ីមែលអំពីវិធីផ្លាស់ប្តូរ៖** www.philasd.org/language/khmer/help

## ពង្រឹងដៃគូល្អ ដើម្បីកែលម្អ សន្តិសុខ និងសណ្តាប់ធ្នាប់ នៅសាលា

**ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា** សប្តាហ៍នេះ បានប្រកាស អំពីប្រាក់ជំនួយចំនួន ៧៣០.៦៧៦$ ដែលបានទទួលពី Philadelphia Foundation’s Fund for Children សម្រាប់ចាយក្នុងរយៈពេលច្រើនឆ្នាំ ដើម្បីកែលម្អ សន្តិសុខ និងសណ្តាប់ធ្នាប់។ សាលាដែលគេជ្រើសរើសឲ្យទទួលការបម្រើក្រោមប្រាក់ជំនួយនេះ ដោយសារសាលាទាំងនេះនឹងទទួលសិស្សានុសិស្សថ្មី នៅសរទរដូវនេះ។ សាលាទាំងនេះនឹងបង្កើតកម្មវិធីពីរ ការធ្វើអន្តរាគមន៍ និងការគាំទ្រឲ្យមានអាកប្បកិរិយាល្អ (PBIS) និងការស្តារឡើងវិញ។ កម្មវិធី PBIS និងមាននៅតាមសាលាទាំងនេះ៖ Penrose, Rhodes, Lea, Rudolph, Hartranft, Tilden, Duckrey, Roberto Clemente, Martha Washington និង William McKinley។ កម្មវិធីការស្តារឡើងវិញ នឹងមាននៅសាលាទាំងនេះ៖ Ben Franklin, High School of the Future, John Bartram, Martin Luther King, Morris E. Leeds, Overbrook High School, Robert Morris, Roxborough, South Philadelphia, និង Harding។

●●●

**តាមរយៈការចាប់ផ្តើមកម្មវិធីសន្តិសុខតាមផ្លូវ (Safe Corridor)** ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា និងក្រសួងជាច្រើនទៀត នៅក្នុងទីក្រុង រួមមាន ស្នងការប៉ូលីសក្រុង ក្រុមហ៊ុនរថយន្តក្រុង SEPTA និងការិយាល័យផ្នែកអ្នកស្ម័គ្រចិត្ត នឹងសហការគ្នា ដើម្បីបង្ហាញផ្លូវដែលមានសុវត្ថិភាពបំផុតសម្រាប់សិស្សានុសិស្សធ្វើដំណើរ ទៅ និង មកពីសាលា។ ជាពិសេស ក្រុមនេះនឹងរកមើលកន្លែងមានមនុស្សកុះករ ផ្លូវប្រសព្វធំៗ ផ្លូវធំៗ និងលក្ខណផ្សេងៗទៀត ដែលអាចទាក់ទងដល់សុវត្ថិភាពរបស់សិស្សានុសិស្ស។ គេនឹងយកយោបល់របស់ក្រុម ដើម្បីរកផ្លូវថ្មី សម្រាប់ឲ្យសិស្សធ្វើដំណើរ និងសម្រាប់ចាត់ឲ្យមានអ្នកមើលក្មេងឆ្លងថ្នល់។ ចៅហ្វាយក្រុង Michael A. Nutter បានបន្ថែម Safe Corridor ១០ ក្រុមទៀត សម្រាប់ថវិកាក្រុង ដើម្បីជួយដល់សិស្សានុសិស្ស និងក្រុមគ្រួសារ។

●●●

ចាប់ផ្តើមនៅសរទរដូវនេះ **វិទ្យាល័យ សោថ ហ្វីឡាដែលហ្វ្យ៉ា និង វិទ្យាល័យ ម៉ាទីន លូហ្សេី ឃីង** នឹងសហការជាមួយ Outward Bound ជាក្រុមឈានមុខ មានបទពិសោធន៍ ក្នុងការផ្តល់កម្មវិធីដឹកនាំតាមបរិវេណខាងក្រៅ។ តាំងពីឆ្នាំ១៩៦២ Outward Bound បាននាំមនុស្សជាង១លាន ទៅកន្លែងផ្សេងៗ ដើម្បីពង្រឹងលក្ខណសម្បត្តិ បង្រៀនឲ្យមានចំណេះដឹងជាអ្នកដឹកនាំ និងញ៉ាំងឲ្យមានការបម្រើប្រកបដោយសីលធម៌។ សិស្សានុសិស្សពីវិទ្យាល័យ សោថ ហ្វីឡាដែលហ្វ្យ៉ា វិទ្យាស្ថានបច្ចេកទេស Bok និង MLK នឹងចូលរួមក្នុងការកសាងក្រុមការងារ និងការហ្វឹកហ្វឺនអ្នកដឹកនាំ ជាមួយ Outward Bound នៅសរទរដូវ។ ការសហការនេះបានបង្កើតឡើងតាមរយៈ ការិយាល័យផ្នែកអ្នកគាំទ្រឲ្យមានសន្តិសុខនៅសាលា និង បណ្តាញយុវវ័យនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា។ ដើម្បីជ្រាបព័ត៌មានបន្ថែមអំពី Outward Bound សូមមើលវ៉ិបសៃ www.outwardbound.org។

●●●

**វិទ្យាល័យ ម៉ាទីន លូហ្សេី ឃីង (MLK)** នឹងសហការជាមួយ Philadelphia Urban Youth Racing School នៅឆ្នាំក្រោយ ក្នុងការប្រឹងប្រែងដើម្បី ពង្រីក និងកែលម្អ កម្មវិធីវិស្វកម្មរថយន្ត។ Urban Youth បានបង្កើតឡើងនៅឆ្នាំ១៩៩៨ ជំរុញឲ្យសិស្សានុសិស្សរៀនយកជំនាញ ផ្នែកវិទ្យាសាស្ត្របច្ចេកទេស វិស្វកម្ម និងគណិតវិទ្យា (STEM)។ ការសហការនេះ នឹងនាំឲ្យមានសិស្សានុសិស្សកាន់តែច្រើន ក្នុងវិស័យ សិក្សា និងកីឡា នៃការប្រកួតប្រជែងផ្នែករថយន្ត ក្នុងពេលដែលយើងបង្រៀនពួកគេអំពីពាណិជ្ជកម្ម នៃឧស្សាហកម្មរថយន្ត។ ដើម្បីជ្រាបព័ត៌មានបន្ថែម សូមមើលវ៉ិបសៃ www.uyrs.com។

## លេខដែលគេខ្វស្សាទូរស័ព្ទ

| បើសិនជាលោកអ្នកមានសំណួរអំពី… | លេខទូរស័ព្ទ |
|---|---|
| **ការបង្កើន និងការគាំទ្រដល់ ការសិក្សា**<br>ផ្តល់ការណែនាំ និងការហ្វឹកហ្វឺនផ្នែកការងារដល់គ្រូ ផ្នែក ដន្ត្រី សិល្បៈ របាំ ល្ខោន កាយវប្បកម្ម ក្រៅម៉ោងសិក្សា កីឡា បណ្ណាល័យ និង ភាសាបរទេស | ២១៥-៤០០-៥៩២០ |
| **វត្តមានអវត្តមាន និងការគេចសាលា**<br>ផ្តល់ជំនួយដល់សាលា ដើម្បីកែលម្អវត្តមានអវត្តមាន និងកាត់បន្ថយការគេចសាលា របស់សិស្ស | ២១៥-៤០០-៤២២០ |
| **ការអប់រំអំពី អាជីព និងបច្ចេកវិទ្យា**<br>ផ្តល់កម្មវិធី និងសេវា សម្រាប់សិស្សានុសិស្សចូលរួមក្នុងការអប់រំអំពី អាជីព និងបច្ចេកវិទ្យា | ២១៥-៤០០-២៣៣១ |
| **ថ្នាក់មុនមត្តេយ្យ**<br>ផ្តល់កម្មវិធី និងជំនួយ សម្រាប់ក្មេង ចាប់ពីពេលកើត ដល់ អាយុប្រាំមួយឆ្នាំ និងក្រុមគ្រួសាររបស់ពួកគេ | ២១៥-៤០០-៤២៧០ |
| **ការចូលរួមរបស់ ក្រុមគ្រួសារ និងសហគមន៍**<br>ធ្វើឲ្យក្រុមគ្រួសារ និងសហគមន៍ អាចទាក់ទង និងអាចចូលរួមក្នុង កម្មវិធី និងជំនួយ របស់ក្រសួង | ២១៥-៤០០-៤១៨០ |
| **ការអប់រំផ្នែកភាសាចម្រុះ**<br>ផ្តល់ជំនួយ និងការគាំទ្រ ផ្នែកភាសាចម្រុះ ដល់សិស្សានុសិស្ស និងក្រុមគ្រួសារ | ២១៥-៤០០-៤២៤០ |
| **ការចាត់តាំងសិស្ស**<br>វាយតម្លៃសំណើសុំផ្លាស់ប្តូរសាលារបស់សិស្ស ហើយសម្រេចការចាត់តាំងសិស្សទៅតាមសាលា | ២១៥-៤០០-៤២៩០ |
| **សំណុំឯកសាររបស់សិស្សានុសិស្ស**<br>រក្សា និង រៀបចំសំណើសម្រាប់សំណុំឯកសាររបស់សិស្ស<br>(ព្រឹត្តិបត្រពិន្ទុ ការបញ្ជាក់អះអាង ដីកា សំណុំឯកសារសិស្សពិការ ។ល។) | ២១៥-៤០០-៤៧៨០ |
| **ការបម្រើពិសេស** ផ្តល់ការអប់រំពិសេស ជំនួយពិសេស និងការបម្រើផ្នែកសុខភាពរបស់សិស្ស | ២១៥-៤០០-៤១៧០ |
| **សន្តិសុខរបស់សាលា**<br>ចូលរួមជាមួយ រដ្ឋបាលសាលា ប៉ូលីស សិស្សានុសិស្ស មាតាបិតា និងសមាជិកសហគមន៍ ដើម្បីបង្កើនសុវត្ថិភាពរបស់សិស្ស នៅក្នុង និងនៅជុំវិញ សាលា | ២១៥-៤០០-៤៧១០ |
| **យានជំនិះ**<br>ផ្តល់យានជំនិះដែលមានសុវត្ថិភាពដល់សិស្សានុសិស្ស នៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យ៉ា ដែលទៅរៀននៅសាលារដ្ឋ សាលាឆាធ័រ សាលាសាសនា និងសាលាឯកជន | ២១៥-៤០០-៤៣៥០ |
| **ព័ត៌មានទូទៅ** | ២១៥-៤០០-៤០០០ |




## បញ្ជីផ្ទៀងផ្ទាត់អំពីអ្វីៗដែលត្រូវធ្វើសម្រាប់បវេសនកាល

*ប្រើបញ្ជីផ្ទៀងផ្ទាត់អំពីអ្វីៗដែលត្រូវធ្វើសម្រាប់បវេសនកាលរបស់យើង ដើម្បីត្រៀមខ្លួនសម្រាប់ថ្ងៃចូលរៀនដំបូង!*

- ▢ **ស្គាល់សាលារបស់កូន សម្រាប់ឆ្នាំ២០១៣-១៤។** សិស្សានុសិស្សទាំងអស់គប្បីបានទទួលលិខិតពីការិយាល័យចុះឈ្មោះ និងចាត់តាំងសិស្ស។ បើសិនជាលោកអ្នកមិនបានទទួលលិខិតនេះទេ សូមទូរស័ព្ទមកលេខ ២១៥-៤០០-៤២៩០។

- ▢ **ពិនិត្យមើលប្រក្រតិទិនសាលាសម្រាប់ឆ្នាំក្រោយ។** ប្រក្រតិទិនសម្រាប់ការសិក្សាឆ្នាំក្រោយ មាននៅក្នុងវិបសៃឥឡូវនេះ www.philasd.org/language/khmer/calendar។ ថ្ងៃទី៩ ខែកញ្ញា គឺជាថ្ងៃបវេសនកាលដំបូង។

- ▢ **សូមចុះឈ្មោះដើម្បីទទួល ព័ត៌មាន និងដំណឹងថ្មីៗ អំពីការផ្លាស់ប្តូរ។** ដើម្បីជ្រាបព័ត៌មានបន្ថែម សូមទាក់ទងតាមវិបសៃ www.philasd.org/language/khmer/help។

- ▢ **ការសម្រេចផែនការអំពីយានជំនិះ។** ការិយាល័យផ្តល់យានជំនិះនឹងសម្រេចថាតើសិស្សណាមានសិទ្ធិជិះយានជំនិះសាលា និងប័ណ្ណជិះ រថយន្តក្រុង និង SEPTA ដោយយោងទៅលើការតម្រូវរបស់រដ្ឋ និងច្បាប់របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា។ បើសិនជាកូនលោកអ្នកមានសិទ្ធិទទួលការបម្រើផ្នែកយានជំនិះ លោកអ្នកនឹងទទួលលិខិតពីការិយាល័យផ្តល់យានជំនិះ នៅរដូវក្តៅនេះ។

- ▢ **រៀបចំសម្រាប់ឯកសណ្ឋានសាលា។** គេតម្រូវឲ្យសិស្សានុសិស្សរបស់ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យាទាំងអស់ ស្លៀកពាក់ឯកសណ្ឋាន។ ដើម្បីមើលច្បាប់សម្រាប់ឯកសណ្ឋានសម្រាប់សាលារបស់កូនលោកអ្នក សូមមើលវិបសៃអំពីការបើកសាលា www.philasd.org/language/khmer/uniform-code។

- ▢ **ចូលរួមក្នុងការជួបជុំគ្នាជាមួយ ក្រុមគ្រួសារ និងការអប់រំ។** សូមចូលរួមជាមួយយើងខ្ញុំ ក្នុងការជួបជុំគ្នាជាមួយ ក្រុមគ្រួសារ និងការអប់រំ នៅថ្ងៃសៅរ៍ ទី១០ ខែសីហា ពីម៉ោង ៨ ព្រឹក ដល់ ៥ ល្ងាច មាន សម្ភារៈចែកជូនដោយឥតគិតថ្លៃ សិក្ខាសាលាអំពីការអប់រំ និងអ្វីៗជាច្រើនទៀត! កម្មវិធីនេះនឹងប្រព្រឹត្តទៅនៅ វិទ្យាល័យ School of the Future អាស័យដ្ឋានលេខ 4021 Parkside Ave.។

- ▢ **ចូលរួមក្នុងការដើរមើលសាលា៖** ការិយាល័យទំនាក់ទំនងជាមួយ ក្រុមគ្រួសារ និងសហគមន៍ បានរៀបចំថ្ងៃសម្រាប់ការដើរមើលសាលា សម្រាប់សាលាដែលទទួលសិស្ស នីមួយៗ។ បញ្ជីសម្រាប់ការដើរមើលសាលា នឹងមាននៅក្នុងវិបសៃ ការបើកសាលា នៅពាក់កណ្តាលខែកក្កដា។

## សូមរក្សាការទាក់ទងជាបន្ត!

សូមចុចរូបភាពខាងក្រោមនេះដើម្បីជ្រាបព័ត៌មានលម្អិត




